**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

លេខ៖ បព ៦២/២០២៥ កបទ.សអ

**សេចក្តីប្រកាសព័ត៌មាន**

**ការធ្វើបទបង្ហាញជូនអង្គទូតស្តីពីលទ្ធផលស៊ើបអង្កេតបឋមលើការបាញ់ប្រហារដោយកងកម្លាំងថៃ លើជនស៊ីវិលកម្ពុជានៅភូមិព្រៃចាន់**

នៅរសៀលថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៥ លោកជំទាវ អ៊ាត សោភា រដ្ឋលេខាធិការប្រចាំការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានដឹកនាំការធ្វើបទបង្ហាញជូនសមាជិកនៃអង្គទូត និង តំណាងអង្គការអន្តរជាតិពាក់ព័ន្ធប្រចាំនៅរាជធានីភ្នំពេញ ស្តីអំពីលទ្ធផលនៃការស៊ើបអង្កេតបឋមលើ ការបាញ់ប្រហារមកលើជនស៊ីវិលកម្ពុជា ដោយកងកម្លាំងប្រដាប់អាវុធថៃ កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ២០២៥ នៅភូមិព្រៃចាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។

យោងតាមលទ្ធផលនៃការស៊ើបអង្កេតបឋមក្នុងបទបង្ហាញ ការបាញ់ប្រហារដោយកងកម្លាំងថៃគឺ ដោយគ្មានការបង្កហេតុញុះញង់ ហើយបានបណ្តាលឱ្យជនស៊ីវិលកម្ពុជាម្នាក់ស្លាប់ និងបីនាក់ទៀតរង របួស នៅរសៀលថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥។ ពុំមានការផ្ទុះអាវុធពីសំណាក់កងកម្លាំងកម្ពុជានៅមុន ឬក៏នៅក្រោយពេលដែលកងកម្លាំងថៃបាញ់ប្រហារចូលទៅក្នុងភូមិនេះទេ។ នេះគឺជាលទ្ធផលនៃការស៊ើប អង្កេតនៅទីតាំងកើតហេតុក្នុងភូមិព្រៃចាន់ ដែលអនុវត្តដោយនគរបាលជាតិកម្ពុជា នៅព្រឹកថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៥ ដោយមានការចូលរួមពីក្រុមសង្កេតការណ៍អាស៊ាន(AOT)។

លោកជំទាវរដ្ឋលេខាធិការប្រចាំការបានបញ្ជាក់ជាថ្មីថា កម្ពុជានៅតែប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះ ការអនុវត្តពេញលេញនូវកិច្ចព្រមព្រៀងឈប់បាញ់ កាលពីថ្ងៃទី២៨ ខែកក្កដា និងសេចក្តីថ្លែងការណ៍រួម ទីក្រុងគូឡាឡាំពួរ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥។ លោកជំទាវបានបញ្ជាក់ជាថ្មីនូវការបដិសេធយ៉ាងដាច់ អហង្ការរបស់កម្ពុជា ចំពោះការចោទប្រកាន់ថាកងកម្លាំងកម្ពុជាបានដាក់មីនថ្មី ហើយបានសម្តែងការ សោកស្តាយយ៉ាងខ្លាំង ដែលប្រទេសថៃបានសម្រេចចិត្តផ្អាកការអនុវត្តសេចក្តីប្រកាសរួមទីក្រុងគូឡាឡាំពួរ បន្ទាប់ពីឧបទ្ទវហេតុទាហានថៃជាន់មីនផ្ទុះ នៅថ្ងៃទី១០ខែវិច្ឆិកា ឆ្នាំ២០២៥ ក្នុងពេលដែលពួកគេចូល ទៅតំបន់ចំការមីនចាស់ក្នុងដែនដីកម្ពុជា យោងតាមផែនទីផលិតដោយគណៈកម្មការចម្រុះបារាំង-សៀម ដែលតុលាការយុត្តិធម៌អន្តរជាតិបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់សាលក្រមឆ្នាំ១៩៦២ និងឆ្នាំ២០១៣។

ថ្ងៃពុធ ៦កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០២៥

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

KINGDOM OF CAMBODIA
NATION RELIGION KING

MINISTRY OF FOREIGN AFFAIRS
AND INTERNATIONAL COOPERATION

No. PR 62/2025 MFA.IC

PRESS RELEASE

**Diplomatic Briefing on Finding of the Preliminary Investigation into the Shooting by Thai Forces on Cambodian Civilians in Prey Chan Village**

In the afternoon of 25 November 2025, Her Excellency Eat Sophea, Permanent Secretary of State of Foreign Affairs and International Cooperation, led a briefing to members of the diplomatic corps and relevant International Organizations in Phnom Penh on the outcome of a preliminary investigation into the shooting of Cambodian civilians by Thai armed forces on 12 November 2025, in Prey Chan village, O Bei Chorn Commune, O Chrov District, Banteay Meanchey Province.

According to the findings presented at the briefing, the shooting by Thai forces was unprovoked and resulted in the death of one Cambodian civilian and injuries to three others, in the afternoon of 12 November 2025. There was no gunfire from the Cambodian armed forces either before or after Thai forces opened fire into the village. The findings are from an on-site investigation at Prey Chan Village, conducted by the Cambodian National Police on the morning of 13 November 2025, with the participation of the ASEAN Observation Team ( AOT ).

Her Excellency the Permanent Secretary of State reaffirmed that Cambodia remains firmly committed to the full implementation of the ceasefire agreement of 28 July and the Kuala Lumpur Joint Declaration of 26 October 2025. She reiterated Cambodia's strong rejection of allegations that Cambodian forces had laid new landmines, and expressed deep regret that Thailand decided to suspend the implementation of the Kuala Lumpur Joint Declaration, after a landmine explosion on 10 November 2025, involving Thai soldiers who entered a landmine contaminated area well within the territory of Cambodia as reflected in the map produced by the Franco-Siamese Mixed Commission and relied upon by the International Court of Justice in its 1962 and 2013 judgments.

Phnom Penh, 26 November 2025

Address : N° 3, Samdech HUN Sen Street,
Sangkat Tonle Bassac, Khan Chamkarmon
Phnom Penh, Kingdom of Cambodia

Tel : (855) 23 216 122
Fax : (855) 23 216 141, 023 213 341
Email : mfaic@mfaic.gov.kh